សាលាសាធារណៈភតឡែន

5

# សេចក្ដីណែនាំ អំពីការសិក្សា សម្រាប់គ្រួសារសិស្សសាលា

សេចក្ដីសង្ខេបអំពីអ្វីខ្លះ ក្មេងៗ គួរដឹង គួរធ្វើ
និងមធ្យោបាយនានា សម្រាប់គ្រួសារទាំងឡាយ បង្កើនការ
រៀនសូត្រនៅតាមគេហដ្ឋានរៀងៗខ្លួន ។




"យើងមានជំនឿថា គ្រប់គ្រួសារសិស្សសាលា គឺជាដៃគូ របស់យើង ។ ពួកគេទាំងនោះ គឺជាគ្រូដំបូង និងជាគ្រូដ៏មានអំណាចខ្លាំងក្លាលើសមនុស្សភាគច្រើន ចំពោះកូនទាំងឡាយ របស់ខ្លួន ។ ដោយការរួមសហការជាមួយគ្នា យើងនឹងអាចធានាថា សិស្សគ្រប់រូប នឹងមានជ័យជំនះ ក្នុងការរៀន របស់នាង"

-អគ្គនាយកសាលាសាធារណៈភតឡែន លោក អ៊ីម៉ែននូអែល ខក

ថ្នាក់ទី៥

## អំពីការណែនាំ ក្នុងការរៀនសូត្រទាំងនោះ:

ការណែនាំនេះ ជាតំណាងដំណឹងសំខាន់មួយ ដែលកូន របស់អ្នកគួរដឹង យើអាចធ្វើបាន មុននឹងដាច់ឆ្នាំសិក្សានេះ ជាភាសាអង់គ្លេសនិងលេខគណិត្រ ។ ទិសដៅ នៃការរៀនសូត្រនានា តែងជួយ គ្រួសារសិស្សនិងលោកគ្រូ/អ្នកគ្រូ បានជ្រាប ពេលណា ដែលសិស្សត្រូវការជំនួយបន្ថែម និងពេលណា ដែលគេត្រូវការមេរៀនសុក្រឹត ។

## តើគ្រួសារសិស្ស អាចធ្វើអ្វីបានខ្លះ ?

វាមានមធ្យោបាយជាច្រើន ដែលអ្នកអាចជួយការរៀនសូត្រ របស់កូនអ្នកបាន និងជួយពួកគេ ដើម្បីស្វែងរកអនាគត របស់គេ ។ តទៅនេះ គឺជាជំនួយខ្លះៗ ដែលនឹងអាចជួយសិស្ស ក្នុងការរៀនសូត្រ:

1. សូមប្រាប់កូនថា ការសិក្សាជាការសំខាន់ របស់កូន ។ ប្រាប់ពួកគេថា ការសិក្សាគឺជាអធិធាតុចម្បង គឺថា ជាប្រភព នៃជ័យជំនះ ។
2. ចាត់ទុកសាលារៀន ជាជំហានមុខ ។ នាំកូនចូលសាលារៀន តាមពេលម៉ោង រៀងរាល់ថ្ងៃ ។
3. រួមសហការជាមួយសាលារៀន ដើម្បីបង្ហាញ នូវការគោរពគ្នាទៅវិញទៅមកជាមួយលោកគ្រូ/អ្នកគ្រូ និងបុគ្គលិក ។
4. សូមបង្ខំកូន ឱ្យធ្វើកិច្ចការរៀនសូត្រ ដោយខ្លួនឯង នាងអាចធ្វើខុសបាន ហើយត្រូវមានភាពទទួលខុសត្រូវ ចំពោះទង្វើទាំងឡាយ របស់ខ្លួន ។
5. និយាយជាមួយកូន អំពីអ្វី ដែលកំពុងតែកើតមាននៅសាលារៀន ។
6. ពិភាក្សាជាមួយគ្រូ របស់កូនអ្នក ដើម្បីធានាថា ពួកគេមានការរីកចម្រើន ក្នុងឆ្នាំសិក្សានិមួយៗ ។
7. ចូលប្រជុំជាមួយគ្រូ និងពិធីជួបជុំដទៃទៀត នៅសាលារៀន តាមដែលអាចធ្វើទៅបាន ។
8. អ្នកមានសិទ្ធិទទួលដំណឹង អំពីការសិក្សា របស់កូន ។ សូមកុំខ្លាចក្រែង ក្នុងការទាក់ទងគ្រូ របស់កូន បើមានសំណួរ ។

## ការពិភាក្សាជាមួយនិងគ្រូ នៃកូន របស់អ្នក

វាជាការមួយយ៉ាងសំខាន់ ក្នុងការសន្ទនាជាមួយគ្រូកូនអ្នកនិងសាលារៀនជាធម្មតា អំពីការរីកចម្រើន ទៅនិងទិសដៅរៀនសូត្រ របស់កូន ។ ខាងក្រោមនេះ ជាសំណួរឬប្រធានបទនានា ដែលអ្នកគួរពិភាក្សា ជាមួយគ្រូបង្រៀន:

- សូមពិនិត្យការណែនាំ អំពីការរៀនសូត្រនេះ ហើយសួរថា ចំណុចខ្លាំង របស់កូនគឺអ្វីខ្លះ និងត្រូវការកែលម្អលើចំណុចណាខ្លះ ។
- បន្ថែមពីលើគោលដៅ នៃការសិក្សាទាំងនោះ ក្នុងការណែនាំនេះ តើវានៅមានគោលដៅដទៃណាមួយទៀត សម្រាប់កូន របស់អ្នកឬទេ?
- សុំគ្រូមើលសំណៅសិក្សា របស់កូន តើគេរៀនបានសម្រេចតាមទិសដៅឬទេ ។
- សួរគេថា ការធ្វើតិសចំណេះវិជ្ជា របស់សិស្ស ដោយវិធីណា ក្នុងរយៈមួយឆ្នាំ នៃការសិក្សានោះ ។
- សួរគ្រូថា តើកូនអ្នករៀនបានសម្រេច តាមគោលបំណង នៃកម្រឹតថ្នាក់ របស់នាងឬទេ ។ បើពុំដូច្នោះទេ តើសាលាមានជំនួយអ្វី សម្រាប់នាងឬទេ? តើអ្នកជាមាតាបិតា អាចជួយអ្វីបានខ្លះ នៅផ្ទះ?

- សួរគ្រូថា តើកូនអ្នករៀនបានសម្រេច តាមការរំពឹងទុកជាមុនឬក៏ប្រសើរជាងការរំពឹងទុក ។ បើពុំដូច្នោះទេ តើសាលាមានជំនួយអ្វី សម្រាប់នាងឬទេ? តើអ្នកជាមាតាបិតា អាចជួយអ្វីបានខ្លះ នៅផ្ទះ?

## និយាយជាមួយកូនអ្នក

"តើមានការសប្បាយរីករាយសុខទុក្ខយ៉ាងណា នៅសាលាថ្ងៃនេះ?"
"សុខសប្បាយជាធម្មតាទេ"
"តើកូនបានធ្វើអ្វីខ្លះនៅសាលាថ្ងៃនេះ?"
"គ្មានធ្វើអ្វីទេ"

តើអ្នកធ្លាប់បានឮសំណួរ/ចម្លើយទាំងនេះឬទេ? មិនអីទេ តោងតែសួរបន្តទៅទៀត ! សិស្សទាំងឡាយ ដែលឪពុកម្តាយគេ តែងតែសាកសួរ អំពីការរៀនសូត្រ តែងតែរៀនសូត្របានល្អប្រសើរនៅ សាលារៀន ។ តទៅនេះ ជាមធ្យោបាយខ្លះៗ ដែលអ្នកអាចទាក់ទាញកូន និងជួយឱ្យនាងរៀនបានសម្រេចៈ

- សូមឆ្លៀតឱកាសនិយាយជាមួយកូនអ្នក អំពីសាលារៀនឱ្យបានរៀងរាល់ថ្ងៃ ។
- សូមឱ្យកូននិយាយប្រាប់អ្នក អំពីអ្វីមួយ ដែលនាងបានរៀន នៅថ្ងៃនេះ ។ អ្វី ដែលកូនអ្នកតែងគិត តែងតែគួរឱ្យចាប់អារម្មណ៍ជាទីបំផុត ។ តើមានអ្វី ដែលគួរឱ្យពិបាកឬទេ ?
- សូមពិនិត្យឡើញវិញ នូវក្រដាសនិងគម្រោងការសិក្សាទាំងឡាយ ដែលកូនអ្នកយកពីសាលារៀន ។ សួរកូនឱ្យប្រាប់អ្នកថា តើក្រដាសឬគម្រោងការសិក្សានោះ ចង់បង្រៀនកូន អំពីអ្វីខ្លះ ។
- សូមសរសើរកូនអ្នក ចំពោះការប្រឹងរៀនសូត្រនិងការព្យាយាម កុំគិតតែពីចម្លើយត្រឹមត្រូវពេក ។
- សួរកូនថា តើនាងកំពុងតែគិត អំពីអ្វីៈ តើនាងដឹង ដោយវិធីណា? តើនាងគិតថាដូចម្តេច? តើនាងមានកត់សម្គាល់លើអ្វីទេ? តើហេតុអ្វី បានជានាងគិតដូច្នោះ? តើនាងមានមធ្យោបាយ ដទៃទៀត ដើម្បីរកចម្លើយឬទេ?

## ជំនួយការរៀនសូត្រ ក្រៅពីសាលារៀន

ការរៀនសូត្រ មិនត្រូវបញ្ចប់ទេ ពេលណា ដែលសិស្សចេញពីសាលារៀននោះ ។ សិស្សទាំងឡាយ ចំណាយពេលក្រៅសាលារៀន ច្រើនជាងនៅសាលារៀន ។ ខាងក្រោមនេះ ជាមធ្យោបាយខ្លះៗ អ្នក អាច ជួយបង្រៀនកូន ក្រៅសាលារៀនៈ

- សូមអានឱ្យកូនស្តាប់ អានជាមួយនិងកូន ហើយណាត់ពេលមួយ ដើម្បីគ្រួសារទាំងមូល អានជុំគ្នា - ជាភាសាណាមួយ ដែលអ្នកអានបានល្អ ។
- រកទីកន្លែងស្ងាត់ស្ងៀម និងមានបរិយាកាសល្អ សម្រាប់កូនអ្នកធ្វើកិច្ចការសាលាឬកិច្ចការរៀនសូត្រ ដទៃទៀត ។
- ព្យាយាមបង្កើតពេលវេលាទៀងទាត់ សម្រាប់ធ្វើកិច្ចការសាលាឬក៏កិច្ចការរៀនសូត្រដទៃទៀត ។
- ប្រើការណែនាំនេះ សង្កត់ធ្ងន់លើគោលដៅរៀនសូត្រមួយចំនួន។ សាកល្បងអនុវត្ត នូវទ្រឹស្តីខ្លះ ដែលបានជម្រាបមកខាងលើនេះ នៅផ្ទះ ។

# តើសិស្ស របស់អ្នកត្រូវការដឹង អំពីអ្វី ហើយនឹងអាចធ្វើអ្វី ក្នុងភាសាអក្សរសាស្ត្រ:

## ភាសា

- ❑ ប្រើការសម្ភាសន៍ ដើម្បីប្រមូលដំណឹងសម្រាប់ការសាវជ្រាវ មានដូចជា ប្រវត្តិគ្រួសារ ។
- ❑ យល់ន័យភាសាអត្ថបដិរូប(ភាសាពិពណ៌នា ដោយប្រើពាក្យក្រៅពីន័យដើម របស់វា) ឧទាហរណ៍- ពន្លឺព្រះអាទិត្យចែងចាំងហាក់បីដូចជាពន្លឺពេជ្រនៅលើផ្ទៃទឹក ។ "The sun sparkled like diamonds on the surface of the water."
- ❑ យល់ នូវន័យអាថ៌កំបាំងពាក្យ ដែលមានន័យស្រដៀង តែន័យផ្សេងគ្នា ដូចជាពាក្យ cool/cold/icy/ frigid ។

## ការអាន និង អក្សរសិល្ប៍

- ❑ ស្គាល់និងវិភាគគំនិតសំខាន់របស់អត្ថបទ លំនាំរបស់អត្ថបទ និងសេចក្តីអមស៊ីជម្រៅ នៅក្នុងសៀវភៅរឿងពិតឬអត្ថបទ ។
- ❑ ស្គាល់និងវិភាគ នូវរបៀប ដែលអ្នកនិព័ន្ធប្រើការផ្តោះផ្តងសន្ទនានិងការពិពណ៌នានៅក្នុង សៀវភៅប្រលោមលោក ឬសៀវភៅរឿង ។ លំនាំរបស់អត្ថបទ និងសេចក្តីអមស៊ីជម្រៅ នៅក្នុងសៀវភៅរឿងពិតឬអត្ថបទ ។
- ❑ ស្គាល់និងវិភាគ នូវរបៀប ដែលអ្នកនិព័ន្ធប្រើឧបករណ៍សរសេររឿងទាំងឡាយដូចជា ទីកន្លែងកើតហេតុ លក្ខណៈរបស់រឿង ឆាកឈុត នៃសាច់រឿង នៅក្នុងរឿងប្រលោមលោកក៏ដូចជា ក្នុងសៀវភៅនានា ។

## ការសរសេរ

- ❑ ធ្វើវិភាគអក្សរសិល្ប៍និងអត្ថបទនានា ហើយសរសេរយ៉ាងខ្លី ដែលលាយទៅដោយសេច ក្តីអមដកចេញពីសៀវភៅ ដើម្បីធ្វើជាសេចក្តីគាំទ្រគំនិតនានា របស់នាង ។ ឧទាហរណ៍- សរសេរសំបុត្រមួយសន្លឹក ទៅជូនអ្នកនិព័ន្ធឬក៏ក្រុមហ៊ុនណាមួយ ។
- ❑ សរសេររបាយការណ៍សាវជ្រាវមួយ ដោយប្រើពាក្យសម្តីផ្ទាល់ របស់ខ្លួន មានរាយសេចក្តីច្បាស់លា ស់និងសេចក្តីអមរបស់វា ។
- ❑ សរសេរតែងរឿងនានា ដែលមានមានប្រើឧបករណ៍តែងរឿងរបស់ប្រលោមលោកមានដូចជា ឆាក តួរអង្គ និងទីកន្លែងកើតរឿង ។



## មធ្យោបាយនានា ដើម្បីទាក់ទាញក្មេងរៀនអានអក្សរនៅតាមផ្ទះ

- ❑ • ពិភាក្សាអំពីប្រវត្តិគ្រួសារអ្នក ជាមួយនិងកូនរបស់អ្នក ។ បង្ហំកូនឱ្យគិតសំណួរឱ្យបានច្រើន សម្ភាសសមាជិកក្នុងគ្រួសារ ហើយតែងជាសាច់រឿងមួយដាក់ក្នុងសៀវភៅរូបថត របស់សាច់ញាតិនិងខ្សែស្រឡាយជីដូនជីតា ។
- អានឮ នូវសៀវភៅភាគ ជាមួយកូនអ្នករៀងរាល់ថ្ងៃ ។ ពិភាក្សាអំពីឆាក និងតួរអង្គនិមួយៗ ។ ឧទាហរណ៍- តើមានបញ្ហាអ្វីចោទឡើងក្នុងសាច់រឿង? តើតួរឯកដោះស្រាយបញ្ហានោះដោយវិធីណានិងមូលហេតុអ្វី? ប្រៀបធៀបរឿងនោះទៅនិងជីវិតរបស់អ្នក និងសៀវភៅផ្សេងៗទៀតដែលអ្នកបានអានមកហើយជាមួយគ្នា ។
- ទៅមើលទីកន្លែងណាមួយ ដែលមានជាប់ទាក់ទិននិងប្រវត្តិរបស់វា ដូចជា Freedom Trail ឬ Portland Observatory ជាមួយនិងកូនរបស់អ្នក ។ ជ្រើសរើសរកជីវប្រវត្តិនៅបណ្ណាល័យសាធារណៈនរណាខ្លះដែលមានកេរ្តិ៍ល្បីល្បាញនៅក្រុងភទឡៃនេះ ។ និយាយជាមួយកូនអ្នកអំពីវិធីដែលកន្លែងមានប្រវត្តិនិមួយៗ ដែលបង្កើតបាន់ទៅជារឿងរ៉ាវមកទល់បច្ចុប្បន្ននេះ ហើយនិងរបៀបដែលគេធ្វើរឿង អំពីអាគារទាំងនោះ ក្លាយទៅជាកន្លែងគួរជាទីចំណាប់អារម្មណ៍និងសំខាន់សម្រាប់មហាជន ។

Notes:

ម្យ៉ាងវិញទៀត សូមរក្សាការទាក់ទងជាមួយនិងគ្រូ របស់កូនអ្នក ហើយសួរអំពីអ្វីដែលអាចរៀនសូត្រនៅផ្ទះ ហើយ ស្រដៀងគ្នានិងកម្មវិធីការអាននិងកាសរសេរនៅសាលារៀន ។

# តើអ្វី ដែលសិស្សត្រូវយល់ដឹង និងអាចធ្វើបានជាមួយលេខគណិត្រ:

- ដោះស្រាយចំណោទ ក្នុងការធ្វើលេខបូក លេខដក លេខគុណ និងលេខចែក ដោយលេខធំៗ និងមានច្រើនលំដាប់ ។
- យល់ នូវទំនាក់ទំនងរវាងលេខបែងភាគ លេខកណ្តកសញ្ញា និងភាគរយ ។
- ដោះស្រាយ និងធ្វើតំណាងចំណោទ ដោយការប្រើលេខកណ្តកសញ្ញានិងប្រភាគ ។
- ធ្វើតំណាង និងបកស្រាយ នូវទំនាក់ទំនងរូបមន្តពីរដូចជាពេលម៉ោងនិងកម្ពស់ ។ ឧទាហរណ៍-គូសបន្ទាត់តំណាងមនុស្សម្នាក់ បានចម្រើនវ័យពី២ទៅ១០ឆ្នាំ ហើយធ្វើវិភាគថាការចម្រើនវ័យនោះកើតឡើងឆាប់ឬក៏យឺត។
- សម្គាល់ រៀបរាប់ និងប្រៀបប្រដូចសណ្ឋានរាងត្រីកោណ(isosceles, equilateral, and right) ។
- យល់ថា quadrilaterals ខ្លះអាចចាត់ចូលតាមក្រុមលើសពីមួយឡើងទៅ ។
- សម្គាល់ រៀបរាប់ ប្រៀបធៀបរូបរាងសណ្ឋានបីជ្រុង ដូចជា រាងបួនជ្រុងទ្រវែង prisms និងរាងសាជីជ្រុង ។
- រកឱ្យឃើញនិងប្រៀបធៀបបរិមាត្រនិងក្រឡាផ្ទៃ របស់រាងបួនជ្រុងទ្រវែង ។
- រករង្វាស់រង្វាល់និងនិងផ្ទៃការ៉េរបស់រាង rectangular prisms ។
- ប្រមូល ធ្វើតំណាង និងវិភាគលើទិន្នន័យ ។
- ប្រើមធ្យោបាយនិងខ្សែកណ្តាល ដើម្បីទាញយកសេចក្តីសរុប អំពីទិន្នន័យនោះ ។



# ការរៀនលេខគណិត្រនៅឯផ្ទះ

- ឱ្យកូនអ្នកវាស់ប្រវែងគ្រប់ជ្រុងបន្ទប់ក្នុងផ្ទះរបស់អ្នក ហើយបន្ទាប់មក រកប្រវែងបរិមាត្រនិងក្រឡាផ្ទៃ នៃបន្ទប់នោះ ។ ម្យ៉ាងទៀត កូនអ្នកអាចវាស់បន្ទប់ផ្សេងមួយទៀត ហើយប្រៀបធៀបបរិមាត្រនិងក្រឡាផ្ទៃ នៃបន្ទប់ទាំងពីរនោះ ។
- រកមើលឱកាសប្រចាំថ្ងៃ ដើម្បីប្រើលេខធំៗជាមួយកូនអ្នក ។ ឧទាហរណ៍- ប្រៀបធៀបតម្លៃ របស់ឡានមានម៉ាកខុសគ្នា ដែលគេចុះផ្សាយក្នុងកាសែតឬក៏ប្រៀបធៀបប្រជាពលរដ្ឋក្រុងភទន្សែន ជាមួយនិងទីក្រុង របស់ញាតិឬក៏មិត្រភ័ក្តិ ។
- រកមើលលេខបែងភាគនិងភាគរយ ក្នុងការលក់ដូរ នៅហាងក្នុងស្រុក ។ ឱ្យកូនអ្នករកឱ្យឃើញថា តើនាងអាចសន្សំប្រាក់បានប៉ុន្មាន បើទិញរបស់អ្វីមួយនោះ ។
- ប្ដូកនិងដកប្រាក់ដុល្លារនិងសេន ដើម្បីប្រើលេខកណ្ដាកសញ្ញារៀងរាល់ថ្ងៃ ។ បំបូងឱ្យកូនអ្នកទាយ នូវទម្លៃរបស់ ពីបីមុខឡើងទៅ ហើយបន្ទាប់មកធ្វើលេខសរុបជាក្រោយ ។

Notes:

ម្យ៉ាងវិញទៀត សូមរក្សាការទាក់ទងជាមួយនិងគ្រូ របស់កូនអ្នក ហើយសួរអំពីអ្វី ដែលអាចរៀនសូត្រនៅផ្ទះ ហើយ ស្រដៀងគ្នានិងកម្មវិធីរៀនលេខគណិត្រនៅសាលារៀនរបស់កូនអ្នក ។

សាលាសាធារណៈភតឡ្មែន
ការិយាល័យវិជ្ជាបង្រៀន
លេខ ៣៥៣ មហាវិថីខាំបើឡ្មែន
ភតឡ្មែន, រដ្ឋម៉េន ០៤១០១
២០៧ ៨៧៤ ៨១០០
portlandschools.org

លិខិតចេញផ្សាយនេះ បោះពុម្ព ដោយសាលាសាធារណៈភតឡ្មែន ។ អត្ថបទប្រើប្រាស់ និងការកែសម្រួល ដោយមានការអនុញ្ញាត អំពីសាលាសាធារណៈបោះស្តុន ។ អត្ថបទ បន្ថែមពីនោះទៀត ជារបស់ បណ្ឌិត អែនថូនី ម៉ោ ។

Created spring 2014

**Khmer**